ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**អត្ថបទស្រាវជ្រាវ**

# ការលុបចោលកិច្ចសន្យា ដោយសារការឆបោក

រៀបរៀងដោយ៖ ថាត ចាន់ថា

**Page: Mr. That Chantha**
**https://www.facebook.com/thatchantha**

# ការលុបចោលកិច្ចសន្យាដោយសារការឆបោក

អត្ថន័យនៃខ្លឹមសារកិច្ចសន្យា ដែលមានបញ្ញត្តិនៅក្នុងច្បាប់ចាស់ គឺជាការសំដែងឆន្ទៈព្រមព្រៀងរបស់បុគ្គលពីរនាក់ក្នុងការបង្កើត រំលត់ ឬ កែប្រែកាតព្វកិច្ច[1] ចំណែកឯក្រមរដ្ឋប្បវេណីថ្មីដែលជាច្បាប់សារធាតុក៏បានចែងអំពីនិយមន័យនៃកិច្ចសន្យា គឺជាកិរិយាដែលបុគ្គលពីរនាក់ ឬច្រើននាក់ មាន ឆន្ទៈត្រូវគ្នាព្រមបង្កើត កែប្រែ ឬ រំលត់ នូវកាតព្វកិច្ច[2]។ ដូចនេះកិច្ចសន្យាកើតមាននៅពេលមានបុគ្គលពីរនាក់ចូលរួម ដែលយើងហៅថាគូភាគីនៃកិច្ចសន្យា ព្រោះដោយហេតុថាកិច្ចសន្យា គឺជាច្បាប់របស់គូភាគី ហេតុនេះគូភាគីត្រូវអនុវត្តកិច្ចសន្យាឲ្យបានខ្ជាប់ខ្ជួនទៅតាមការព្រៀមព្រៀងរបស់ខ្លួន។ ហេតុនេះការព្រមព្រៀង គឺជាធាតុជាសារវន្តនៃការបង្កើតកិច្ចសន្យា បើគ្មានការព្រមព្រៀងទេ នោះកិច្ចសន្យានឹងមិនមានសុពលភាពឡើយ។ ការព្រមព្រៀងនេះត្រូវតែជាលក្ខខណ្ឌមួយដែលមានសារៈសំខាន់ ព្រោះដោយសារតែការព្រមព្រៀងនេះ ហើយដែលភាគីនីមួយៗ ក្នុងកិច្ចសន្យាសំដែងនូវឆន្ទៈយល់ព្រម របស់ពួកគេលើការបង្កើតកិច្ចសន្យា ហើយដើម្បីឲ្យមានការព្រមព្រៀង វាត្រូវតែមានការជួបគ្នារវាងឆន្ទៈដែលធ្វើឡើងតាមរយៈសំណើ និងការទទួលយកនូវសំណើ ហៅថាស្វីការ[3]។ ម៉្យាងវិញទៀតការព្រមព្រៀងព្រៀង និងបង្ហាញឆន្ទៈក្នុងការបង្កើតកិច្ចសន្យាឲ្យមានអានុភាពគតិយុត្ត គឺជាការព្រមព្រៀងដែលធ្វើ ឡើងដោយពិតប្រាកដ សេរី និងជាក់លាក់។ ការភន្ត័ច្រឡំ ហិង្សា និងការបន្លំបោកប្រាស់ ឬឆបោកត្រូវបានចាត់ទុកថា ជាវិការៈអធ៌មដែលប៉ះពាល់ដល់ការព្រមព្រៀង។ ការបន្លំបោកប្រាស់ ឬការឆបោក គឺជាកិច្ចកលទុច្ចរិតដែលប្រព្រឹត្តដោយគូភាគីណាមួយ ហើយដែលជាកត្តាកំណត់ឲ្យភាគីម្ខាងទៀតចុះកិច្ចសន្យា[4]។ តើការបន្លំបោកប្រាស់ ឬ ការឆបោកត្រូវមានធាតុផ្សំអ្វីខ្លះ? ប្រសិនបើការឆបោកនោះត្រូវបានធ្វើដោយតតិយជន តើកិច្ចសន្យាត្រូវលុបចោលដែរឬទេ? តើការឆបោក គឺជាមូលហេតុនៃលុបចោលនៃកិច្ចសន្យាដែរឬទេ? តើអ្នកណាខ្លះអាចសុំលុបចោលនេះបាន? ដើម្បីស្វែងយល់អំពីផលវិបាកនៃការបន្លំបោកប្រាស់ (II) យើងគួរកំណត់នូវអត្ថសញ្ញាណនៃការបន្លំបោកប្រាស់ជាមុនសិន (I)។

[1] មាត្រា ១ នៃក្រឹត្យច្បាប់លេខ ៣៨ ស្ដីពីកិច្ចសន្យា និងការទទួលខុសត្រូវក្រៅកិច្ចសន្យា ឆ្នាំ១៩៨៨។

[2] មាត្រា ៣១១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[3] មាត្រា ៣៣៦ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[4] មាត្រា ៣៤៧ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

## I/ ការបន្លំបោកប្រាស់ដែលជាមូលហេតុនៃការលុបចោលកិច្ចសន្យា

ការឆបោកឬ ការបន្លំបោកប្រាស់មានលក្ខណៈខុសអំពីការភ័ន្តច្រឡំ ដោយហេតុថាការភន្ត័ច្រឡំ គឺការយល់ និងជឿជាក់ខុសរបស់ភាគីណាមួយដោយមិនមានកិច្ចកលទុច្ចរិតពីភាគីម្ខាងទៀតឡើយ[5]។ ផ្ទុយទៅវិញ ការបន្លំបោកប្រាស់ស្ដែងឡើងតាមរយៈកិច្ចកលឧបាយទុច្ចរិតរបស់ភាគីណាមួយ (១) ដែលធ្វើឲ្យភាគីម្ខាងទៀតយល់ព្រមចុះកិច្ចសន្យាដោយសារអត្ថិភាពនៃកិច្ចកលនោះ (២)។

### ១. អត្ថិភាពនៃកិច្ចកលទុច្ចរិត

កិច្ចសន្យានឹងយកជាការបានលុះត្រាតែកិច្ចសន្យា នោះកើតចេញពីការព្រមព្រៀងពិតប្រាកដ និងដោយសេរី[6]។ កាលណាការព្រមព្រៀងមិនមានពិតប្រាកដ និងសេរីទេនោះ នាំឲ្យកិច្ចសន្យាមានវិការៈនៃការព្រមព្រៀង ហើយបើការព្រមព្រៀងនោះបណ្ដាលមកពីការឆបោក កិច្ចសន្យានឹងត្រូវលុបចោល។ ការបន្លំបោកប្រាស់ ឬ ការឆបោក គឺជាវិការៈអធំមនៃការព្រមព្រៀងមួយ ដែលស្ដែងឡើងតាមរយៈ ឧបាយកល អំពើបោកបញ្ឆោត អំពើបន្លំភូតភរ ប្រព្រឹត្តដោយភាគីណាមួយ។ ប៉ុន្តែនៅក្នុងក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ ដែលបានបញ្ញត្តិនៅក្នុងមាត្រា ៣៤៧ គឺកិច្ចសន្យានឹងត្រូវបានលុបចោល បើកាលណាការបង្ហាញឆន្ទៈនោះមានវិការៈដោយមូលហេតុនៃការឆបោក។ ឥទ្ធិពលនៃកិច្ចកលទាំងនោះ នាំឲ្យភាគីម្ខាងទៀតផ្ដល់ការយល់ព្រមព្រមព្រៀងលើកិច្ចសន្យា ដោយមិនដឹងខ្លួនដែលនេះជាធាតុផ្សំសម្ភារៈ រីឯធាតុអត្តនោម័តវិញ គឺសំដៅដល់ភាគីដែលបានប្រព្រឹត្តកិច្ចកលទុច្ចរិត និងបង្កើតកំហុសដោយចេតនា ទោះបីដឹងថាជាអំពើមិនស្រប ទៅនឹងបញ្ញត្តិនៃច្បាប់យ៉ាងណាក៏ដោយ ប៉ុន្តែនៅតែមានឆន្ទៈក្នុងការបង្កវាឡើយដើម្បីទទួលបានការយល់ព្រមព្រៀងពីភាគីម្ខាងទៀតដែលរងគ្រោះ។

#### ក. អ្នកបង្កកិច្ចកល

កិច្ចកលត្រូវបង្កឡើងដោយគូភាគីនៃកិច្ចសន្យា អាស្រ័យហេតុនេះ យើងអាចកំណត់បានថាកាលណាការបន្លំបោកប្រាស់មានប្រភពចេញពី គូភាគីនៃកិច្ចសន្យា នោះកិច្ចសន្យានឹងត្រូវលុបចោល។ ប្រសិនបើកិច្ចកលឧបាយនោះចេញអំពីតតិយជនវិញ កិច្ចសន្យានឹងមិនត្រូវលុបចោលឡើយ ក្នុងករណីដែលតតិយជនជា

[5] មាត្រា ៣៤៦ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។
[6] មាត្រា ៣ នៃក្រឹត្យច្បាប់លេខ ៣៨ ស្ដីពីកិច្ចសន្យា និងការទទួលខុសត្រូវក្រៅកិច្ចសន្យា ឆ្នាំ១៩៨៨។

ជនសុចរិត ហើយគ្មានកំហុសអំពីការឆបោក មិនអាចអះអាងនូវអានុភាពនៃការលុបចោលចំពោះតតិយជននោះបានឡើយ។ ប៉ុន្តែភាគីរងគ្រោះអាចប្ដឹង នឹងសុំសំណងជម្ងឺចិត្តបានដោយសំអាងទៅលើលក្ខខណ្ឌនៃការទទួលខុសត្រូវរដ្ឋប្បវេណី។ តាមខ្លឹមសារនៃក្រមរដ្ឋប្បវេណី ភាគីនៃកិច្ចសន្យាអាចជារូបវន្តបុគ្គល ឬនីតិបុគ្គល។ តាមន័យទូទៅ គូភាគីនៃកិច្ចសន្យា គឺជាភាគីដែលចុះកិច្ចសន្យាជាមួយភាគីម្ខាងទៀត យើងសួរថាប្រសិនបើកិច្ចកលទុច្ចរិតចេញអំពីសហព័ន្ធ កូន ឬសាច់ញាតិរបស់ភាគីនៃកិច្ចសន្យាដោយមានការដឹង ឬមិនដឹងពីគូភាគីនៃកិច្ចសន្យានោះ ថាតើកិច្ចសន្យានេះអាចត្រូវបានលុបចោលដែរឬទេ? ម្យ៉ាងវិញទៀត សំណួរនេះក៏អាចចោទសួរផងដែរ ប្រសិនបើកិច្ចកលត្រូវបានប្រព្រឹត្តដោយតតិយជនវិញ ប៉ុន្តែមានការសមគំនិតដោយគូភាគីនៃកិច្ចសន្យា។

ជាមួយគ្នានេះដែរ ប្រសិនបើកិច្ចកលត្រូវបានប្រព្រឹត្តដោយតតិយជនសុទ្ធសាធ ដោយគ្មានការចូលរួមគំនិតរបស់គូភាគីនៃកិច្ចសន្យា ប៉ុន្តែកិច្ចកលនោះមានទៅលើធាតុដ៏សំខាន់ ឬជាសំភារៈនៃកិច្ចសន្យា ពោលគឺមានទៅលើសារធាតុ នៃរបស់ដែលជាកម្មវត្ថុនៃកិច្ចសន្យា វាហាក់ដូចជាអយុត្តិធម៌ ចំពោះភាគីរងគ្រោះប្រសិនបើគេមិនអាចប្ដឹង សុំលុបចោលកិច្ចសន្យានេះបាន។ ការព្រមព្រៀងខាងលើមិនត្រូវបានធ្វើដោយពិតប្រាកដ ប៉ុន្តែភាគីរងគ្រោះត្រូវមានកាតព្វកិច្ចអនុវត្តកិច្ចសន្យាទៀត។ នៅក្នុងករណីដែលមានវិការៈនៅក្នុងការបង្ហាញឆន្ទៈ ជនដែលបានបង្ហាញឆន្ទៈដោយមានវិការៈ ឬ អ្នកតំណាងដែលច្បាប់បានកំណត់របស់ជននោះអាចលុបចោលកិច្ចសន្យាបាន ទន្ទឹមនឹងនេះ សន្តតិជនរបស់ជនដែលបង្ហាញឆន្ទៈ ឬជនដែលទទួលបន្តឋានៈនៅក្នុងកិច្ចសន្យាពីអ្នកដែលបង្ហាញឆន្ទៈក៏អាចអនុវត្តសិទ្ធិលុបចោលបានដែរ[7]។

## ខ. លក្ខណៈនៃកិច្ចកល

កិច្ចកលដែលប្រព្រឹត្តដោយភាគីម្ខាងទៀតអាចស្ដែងឡើងតាមរយៈ ឧបាយកល អំពើបញ្ឆោត ឬអំពើបន្លំភូតភរជាដើម[8]។ តាមន័យនេះក្រឹត្យច្បាប់លេខ ៣៨ ផ្ដោតសំខាន់ទៅលើអំពើជាសម្ភារៈ ពោលគឺទាមទារសកម្មភាពដែល ត្រូវបានប្រព្រឹត្តដោយភាគីម្ខាង ដែលអាចជាការកែច្នៃគ្រឿងម៉ាស៊ីនរបស់រថយន្ត ឬ ការនិយាយភូតកុហក។ល។ ចំណុចនេះបង្កើតជាចម្ងល់មួយថា ប្រសិនបើភាគីម្ខាងមិនបានធ្វើអំពើទាំងនោះទេ ប៉ុន្តែគេរក្សាការស្ងប់ស្ងាត់វិញ ពោលគឺធ្វើការលាក់លៀមនូវព័ត៌មាននេះត្រូវបានដឹងដោយភាគីនោះ កិច្ចសន្យា

[7] មាត្រា ៣៥៩ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។
[8] មាត្រា ១១ នៃក្រឹត្យច្បាប់លេខ ៣៨ ស្ដីពីកិច្ចសន្យា និងការទទួលខុសត្រូវក្រៅកិច្ចសន្យា ឆ្នាំ១៩៨៨។

នឹងមិនត្រូវបានចុះឡើយ។ តើការរក្សាភាពស្ងៀមស្ងាត់ខាងលើអាចចាត់ទុកជាការបន្លំបោកប្រាស់ក្នុងអត្ថន័យនៃក្រមរដ្ឋប្បវេណីដែរឬទេ? ក្នុងករណីនេះវាហាក់ដូចជាមិនបានបញ្ជាក់លំអិតពីចំណុចនេះឡើយ ដែលភាគីម្ខាងទៀតមិនបានធ្វើការចចារគ្នាដោយស្មោះត្រង់ និងសុច្ចរិត។ តាមន័យនេះការរក្សាភាពស្ងៀមស្ងាត់ គួរតែចាត់ទុកជាកិច្ចកល ដែលជាមូលហេតុនៃការលុបចោលនៃកិច្ចសន្យា កាលណាការរក្សាភាពស្ងៀមស្ងាត់ត្រូវបានធ្វើទៅលើព័ត៌មានសំខាន់ ហើយប្រព្រឹត្តដោយមានចេតនាដោយភាគីម្ខាងនៃកិច្ចសន្យា។

ភស្តុតាងនៃការបន្លំបោកប្រាស់ មានភាពងាយស្រួលក្នុងការបង្ហាញ ជាជាងភស្តុតាងនៃការភ័ន្តច្រឡំ ពីព្រោះថាភាគីរងគ្រោះគ្រាន់តែបង្ហាញថា មានអំពើកិច្ចកលដែលបង្កឡើងដោយគូភាគី។ ដោយឡែកចំពោះការភន្ត័ច្រឡំវិញ ភាគីដែលភន្ត័ច្រឡំត្រូវបង្ហាញការជឿជាក់ដោយច្រឡំដែលពិបាកក្នុងការបង្ហាញ។ ការបន្លំបោកប្រាស់មិនអាចចេះតែធ្វើការសន្និតបាននោះទេ គឺត្រូវមានការបង្ហាញភស្តុតាងជាចាំបាច់។

## ២. កម្មវត្ថុនៃកិច្ចកល

ការបន្លំបោកប្រាស់ គឺជាអំពើដែលបង្កឲ្យកើតមានការភ័ន្តច្រឡំ។ អ្នកដែលសម្អាងពីការបន្លំបោកប្រាស់ត្រូវធ្វើការបង្ហាញថាកិច្ចកលទុច្ចរិត បានបង្កការភ័ន្តច្រឡំ ដែលជាកត្តាកំណត់ឆន្ទៈរបស់ខ្លួនក្នុងការចុះកិច្ចសន្យា។ ក្នុងអត្ថន័យនេះភាគីរងគ្រោះត្រូវបង្ហាញថា ប្រសិនបើគ្មានកិច្ចកលទាំងនេះទេ នោះខ្លួននឹងមិនចុះកិច្ចសន្យាឡើយ ពោលគឺថា ការបន្លំបោកប្រាស់ គឺជាអ្នកកំណត់ការសំដែងឆន្ទៈរបស់ភាគីម្ខាងទៀត។ អាស្រ័យហេតុនេះហើយទើបទ្រឹស្តីធ្វើការបែងចែករវាងការបន្លំបោកប្រាស់ជាចម្បងនិងការបន្លំបោកប្រាស់បន្ទាប់បន្សំ។

### ក. ការបន្លំបោកប្រាស់ចម្បង

ដើម្បីឆ្លើយតបទៅនឹងខ្លឹមសារនៃក្រឹត្យច្បាប់លេខ ៣៨ ពោលគឺបើគ្មានកិច្ចកលនោះទេ ភាគីម្ខាងទៀតមិនចុះកិច្ចសន្យាឡើយ។ ភាគីម្ខាងទៀតនឹងចុះកិច្ចសន្យាដដែល ប៉ុន្តែក្នុងលក្ខខណ្ឌខាតបង់ខ្លះ ឧទាហរណ៍ការបង់ប្រាក់ក្នុងតម្លៃខ្ពស់ជាងធម្មតា។ ការបន្លំបោកប្រាស់ចំបងនេះទៀតសោត ដែលបង្កឡើងដោយអំពើបញ្ឆោត ឧបាយកលបន្លំមួយរបស់សហចុះកិច្ចសន្យា។ នៅក្នុងខ្លឹមសារនេះឧបាយកល បង្កើតជាការបន្លំបោកប្រាស់ គឺគ្រប់ទង្វើមិនស្មោះត្រង់ ក្នុងគោលដៅបញ្ឆោតភាគីម្ខាង ដើម្បីជំរុញឲ្យមានការចុះកិច្ចសន្យា ដែលប្រភេទទាំងអស់នោះអាចមានដូចជា ឧបាយកលបន្លំ ការភូតភរ កុហកធម្មតាមិនមានធាតុផ្សំខាងក្រៅ និង

តុល្យភាពបានលាក់ទុកដោយភាគីម្ខាង។ ដូច្នេះដើម្បីលាក់បាំងនូវអង្គហេតុអ្វីមួយដែលភាគីម្ខាងទៀត ព្រោះថាបើភាគីនោះបានដឹង នឹងមិនចុះកិច្ចសន្យានោះទេ។

### ខ. ការបន្លំបោកប្រាស់បន្ទាប់បន្សំ

បើគ្មានអំពើជាឧបាយកលនេះទេ ភាគីម្ខាងទៀតនឹងមិនចុះកិច្ចសន្យាឡើយ ប៉ុន្តែជាយុត្តិសាស្ត្រមិនមានភាពច្បាស់លាស់ទេ ជួនកាលម្តងប្រើវិធីនេះ ជួនកាលប្រើវិធីនោះនាំឲ្យភាគីម្ខាងទៀតជឿទុកចិត្ត និងសម្រេចគោលដៅ។ គួរបញ្ជាក់ផងដែរថា ការបន្លំបោកប្រាស់បែបបន្ទាប់បន្សំ មិនមែនជាមូលហេតុនៃការលុបចោលកិច្ចសន្យានោះទេ ប៉ុន្តែជាមូលហេតុស្នើសុំសំណងជម្ងឺចិត្ត។ ដោយឡែក ចំពោះភាគីដែលបង្កការបន្លំបោកប្រាស់វិញ តើកិច្ចកលដែលបង្កនោះគួរត្រូវបានធ្វើឡើងដោយចេតនា ឬយ៉ាងណា? តាមខ្លឹមសារមាត្រា ១០ នៃក្រឹត្យច្បាប់លេខ ៣៨ ការបន្លំបោកប្រាស់សំដៅទៅលើឧបាយកល អំពើបញ្ឆោត ឬអំពើភូតភរដែលធ្វើដោយភាគីម្ខាង។ អាស្រ័យហេតុនេះ យើងអាចសន្និដ្ឋានបានថា ភាគីដែលរងគ្រោះ គ្រាន់តែបង្ហាញថាមានអំពើទាំងនេះត្រូវបានប្រព្រឹត្តដោយភាគីម្ខាងទៀត ដោយមិនចាំបាច់បង្ហាញពីចេតនារបស់ជននោះទេ។ តាមពិតទៅអំពើខាងលើគួរតែបង្កប់នូវចេតនាទុច្ចរិតរបស់ភាគីនោះស្រេចទៅហើយ។ កាលណាអំពើមួយត្រូវបានចាត់ទុកជាបន្លំបោកប្រាស់ នោះភាគីម្ខាងទៀតអាចស្វះស្វែងរកមធ្យោបាយដើម្បីការពារប្រយោជន៍របស់ខ្លួន ដូចជាតាមរយៈការលុបចោលនៃកិច្ចសន្យាជាដើម[9]។

## II/ ផលវិបាកនៃការបន្លំបោកប្រាស់

ការលុបចោល គឺមានន័យថាសុពលភាពតាំងពីដំបូង រហូតដល់លុបចោលបន្ទាប់ពីបានលុបចោលហើយ គេសន្មត់ថាគ្មានសុពលភាពអនុវត្តតាំងពីដំបូងមក[10] ពោលគឺ ការសើរើត្រឡប់ថយក្រោយវិញ ដោយចាត់ទុកថាគ្មានឥទ្ធិពលអ្វីឡើយចាប់ពីដើមទីមក (អានុភាពប្រតិសកម្ម)។ កិច្ចសន្យាដែលអាចលុបចោលបានដោយមូលហេតុមានវិការៈក្នុងការបង្ហាញឆន្ទៈដូចជា ការភន្តច្រឡំ ការបន្លំបោកប្រាស់ ឬ ការឆបោកព័ត៌មានមិនពិត ការរំលោភលើស្ថានភាព ការគម្រាមកំហែង អំពើកេងចំណេញហួសហេតុ អសមត្ថភាពក្នុងការបង្ហាញឆន្ទៈ អនីតិភាពជាដើម។ ចំណែកការឆបោក ឬ ការបន្លំបោកប្រាស់ អ្នកដែលឆបោកភាគីម្ខាងទៀត

[9] មាត្រា ៣៦០ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។
[10] មាត្រា ៣៥៨ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

នឹងត្រូវមានការទទួលខុសត្រូវចំពោះភាគីរងគ្រោះ (១) ហើយនឹងត្រូវទទួលរងនូវបេបគតិយុត្តនៃទណ្ឌកម្មចំពោះការឆបោក ដែលខ្លួនបានប្រព្រឹត្តឡើយ (២)។

## ១. ទណ្ឌកម្មនៃការបន្លំបោកប្រាស់

នៅពេលដែលភាគីណាមួយធ្វើឲ្យមានកំហុស ហើយនាំឲ្យមានការខូចខាត ដល់ភាគីម្ខាងទៀតនោះ នឹងនាំឲ្យមានការទទួលខុសត្រូវ តាមរយៈទណ្ឌកម្មមួយចំនួនដូចជាការលុបចោលកិច្ចសន្យា ការសងជម្ងឺចិត្ត ឬការបង្ខំឲ្យបំពេញកាតព្វកិច្ច ទាំងឡាយដែលខ្លួនមាននៅក្នុងកិច្ចសន្យា។ ការទទួលទណ្ឌកម្មមានពីរប្រភេទ គឺការទទួលទណ្ឌកម្មខាងរដ្ឋប្បវេណី និង ទណ្ឌកម្មខាងព្រហ្មទណ្ឌ។ ការទទួលទណ្ឌកម្មផ្នែករដ្ឋប្បវេណី សំដៅទៅលើការជួសជុលការខូចខាត និងការសងជម្ងឺចិត្តដល់ភាគីដែលទទួលរងគ្រោះ ឬខូចខាត ចំណែកឯទណ្ឌកម្មខាងព្រហ្មទណ្ឌវិញ សំដៅទៅលើទង្វើរបស់ភាគីណាមួយ បានបំពានទៅលើកិច្ចសន្យា ហើយការបំពាននោះមានការប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ ឬផ្ទុយទៅនឹងបទបញ្ញត្តិច្បាប់ដែលបានកំណត់។

ឧទាហរណ៍៖ លោក ល្ពៅ បានជួលរថយន្តពីលោក ត្រឡាច ចំនួនបីគ្រឿង។ នៅក្នុងកិច្ចសន្យារវាងលោក ល្ពៅ និងលោកត្រឡាច បានកំណត់ថាមិនឲ្យលោក ល្ពៅ យករថយន្តនេះទៅប្រើប្រាស់ ឬធ្វើអ្វីមួយដែលមិនត្រូវផ្ទុយនឹងច្បាប់ឡើយ តែលោក ល្ពៅ បានយករថយន្តនោះទៅដឹកគ្រឿងញៀន។ តាមរយៈទង្វើរបស់លោក ល្ពៅ បានធ្វើឲ្យប៉ះពាល់ទៅលើកិច្ចសន្យា រវាងខ្លួន និង លោក ត្រឡាច មិនតែប៉ុណ្ណោះទង្វើរបស់លោក ល្ពៅ មានលក្ខណៈផ្ទុយនឹងច្បាប់ទៀតផង។ ដូច្នេះលោក ល្ពៅ ត្រូវទទួលរងទណ្ឌកម្មពីរ គឺទី១ ទណ្ឌកម្មផ្នែករដ្ឋប្បវេណី នាំឲ្យលោក ល្ពៅ ត្រូវសងការខូចខាត និងសងជម្ងឺចិត្តដល់លោក ត្រឡាច ដោយសារតែលោក ល្ពៅ បានបំពានទៅលើកិច្ចសន្យា និងទណ្ឌកម្មទី២ ផ្នែកព្រហ្មទណ្ឌ គឺលោក ល្ពៅ ត្រូវប្រឈមមុខនឹងច្បាប់ដោយសារតែគាត់បានដឹងគ្រឿងញៀន ដែលទង្វើនេះជាទង្វើដែលច្បាប់ហាមឃាត់។

## ២. របបគតិយុត្តនៃទណ្ឌកម្ម

ដើម្បីធ្វើការលុបចោលកិច្ចសន្យា ត្រូវធ្វើឡើងដោយការជូនដំណឹង ទៅភាគីម្ខាងទៀតនោះ ហើយការលុបចោលនោះ ត្រូវមានអានុភាព នៅពេលដែលដំណឹងនោះបានទៅដល់ភាគីម្ខាងទៀត។ អាជ្ញាយុកាលនៃការរំលត់សិទ្ធិលុបចោលមានរយៈពេល ០៣ឆ្នាំ ចាប់ពីខ្លួនក្លាយជាអ្នកដែលអាចផ្តល់សច្ចានុមតិ និងអំឡុង

ពេល ១០ឆ្នាំ ចាប់តាំងពីកាលបរិច្ឆេទនៃសកម្មភាពនោះ[11]។ ក្រោយពេលអាជ្ញាយុកាលរំលត់ ត្រូវបានបញ្ចប់ នោះជនដែលមានសិទ្ធិលុបចោល មិនអាចលុបចោលសកម្មភាព ដែលអាចលុបចោលនោះទៀតទេ ដូច្នេះ សកម្មភាពនោះត្រូវចាត់ទុកថាមានសុពលភាពជាស្ថាពរ។ ឧទាហរណ៍ នៅក្នុងករណីដែល លោក ម្នាស់ បាន លក់ដីរបស់គាត់ឲ្យទៅលោក កាំបិតចិត ដោយសារការឆបោករបស់ លោក កាំបិតចិត ហើយគាត់បានដឹងអំពី ការណ៏នោះនៅ ១២ឆ្នាំ ក្រោយមក គាត់បានអនុវត្តសិទ្ធិលុបចោលនៅក្នុងរយៈពេល ០៣ឆ្នាំ គិតចាប់តាំងពី ពេលដែល គាត់អាចលុបចោលកិច្ចសន្យានោះ ប៉ុន្តែសិទ្ធិលុបចោលរបស់គាត់ ត្រូវបានរំលត់ទៅហើយ ដោយសារតែអំឡុងពេល ១០ឆ្នាំ បានកន្លងផុតទៅ គិតចាប់ពីកាលបរិច្ឆេទនៃសកម្មភាព[12]។

មូលហេតុដែលក្រម បានចែងនូវការកម្រិតការអនុវត្ត សិទ្ធិលុបចោលទាំងពីរនេះ គឺថាលក្ខខណ្ឌនៃ សកម្មភាព ដែលអាចលុបចោលបាន គឺធ្វើឲ្យទំនាក់ទំនងគតិយុត្តមិនមានស្ថេរភាព ដូច្នេះវាមានលក្ខណៈ សំខាន់ណាស់ ក្នុងការធ្វើឲ្យទំនាក់ទំនងដែលគ្មានស្ថេរភាពនេះ មានស្ថេរភាពឡើងវិញ។ ប៉ុន្តែវាក៏មានភាពចាំ បាច់ដើម្បីការពារ ជនដែលធ្វើសកម្មភាពដែលអាចលុបចោលបាន។ ដូចនេះក្រមរដ្ឋប្បវេណី តម្រូវឲ្យនៅក្នុង ស្ថានភាពដែលជន ដែលមានសិទ្ធិលុបចោលកិច្ចសន្យាបានគ្រប់ពេល គាត់ត្រូវតែអនុវត្តសិទ្ធិរបស់គាត់ឲ្យ បានកាន់តែឆាប់កាន់តែប្រសើរ។ ទន្ទឹមនឹងនេះដែរ ប្រសិនបើមានបុគ្គលច្រើននាក់ មានសិទ្ធិលុបចោល នោះ សិទ្ធិលុបចោលរបស់បុគ្គលម្នាក់ៗត្រូវរលត់រៀងៗខ្លួន[13]។ ឧទាហរណ៍ កញ្ញា សង់ត្យា មានអាយុ ១៦ឆ្នាំ បាន ចុះកិច្ចសន្យាជាមួយតតិយជន ដោយមិនមានការយល់ព្រមពីអ្នកមានអំណាចមេបា សង់ទីឡាសេ។ ក្រោយ មក សង់ទីឡាសេ បានដឹងអំពីរឿងនេះភ្លាម បន្ទាប់ពីពេលបង្កើតកិច្ចសន្យារវាង កញ្ញា សង់ត្យា និង លោក ត្រសក់ស្រូវ។ នៅក្នុងករណីនេះ កញ្ញា សង់ត្យា មិនអាចផ្ដល់សច្ចានុមតិទៅលើសកម្មភាពរបស់កញ្ញានៅមុន ពេល កញ្ញាក្លាយទៅជានីតិជន ដូច្នេះការចាប់ផ្ដើមនៃអាជ្ញាយុកាលរំលត់ ត្រូវគិតចាប់ពីកាលបរិច្ឆេទគំរប់អាយុ ១៨ឆ្នាំ របស់កញ្ញា សង់ត្យា។ គួរបញ្ជាក់ផងដែរថា នៅក្នុងពាក្យច្បាប់ ការសន្មត់ មានន័យថា ការសន្មត់ជាប ណ្ដោះអាសន្នថាវាយ៉ាងដូច្នោះសិន ហើយគេអនុញ្ញាតឲ្យសាម៉ីខ្លួនរកភស្តុតាងមកបញ្ជាក់ ពោលគឺបញ្ជាក់ អះអាងថាវាខុសនឹងការពិត ហើយលុបចោលការសន្មត់នោះ។ ចំណែកឯពាក្យ ការចាត់ទុក មានន័យថាជា ការកំណត់ដោយច្បាប់ថាយ៉ាងនេះ ហើយមិនអាចលុបចោលដោយបញ្ជាក់ផ្ទុយពីនោះបានទេ។

---

[11] មាត្រា ៣៦៣ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[12] មាត្រា ៣៦៣ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[13] មាត្រា ៣៦៣ កថាខណ្ឌទី៣ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

## សេចក្តីសន្និដ្ឋាន

យោងតាមការបកស្រាយរួចមក យើងអាចសន្និដ្ឋានបានថាជាទូទៅ កិច្ចសន្យាដែលត្រូវបានបង្កើតឡើងដោយការព្រមព្រៀងរបស់គូភាគី មានកម្មវត្ថុស្របច្បាប់ ហើយធ្វើឡើងដោយសមត្ថជន នោះកិច្ចសន្យានឹងមានអានុភាពអនុវត្ត។ ក៏ប៉ុន្តែនៅក្នុងករណីមួយចំនួន កិច្ចសន្យាដែលបំពេញគ្រប់លក្ខខណ្ឌខាងលើ នៅតែវាត្រូវបានលុបចោល ដោយសារតែមានវិការៈតាមរូបភាពនៃការបន្លំបោកប្រាស់ ឬ ការឆបោក។ ក្រមរដ្ឋប្បវេណីក៏បានបញ្ញត្តិ អំពីការលុបចោល គឺជាសកម្មភាពឯកតោភាគី ដូចនេះការលុបចោល ត្រូវមានអានុភាពនៅពេលដែលការជូនដំណឹងពីការលុបចោលនោះបានដល់ភាគីម្ខាងទៀត[14]។

សកម្មភាពដែលអាចលុបចោលបាន មានសុពលភាពរហូតដល់ពេល ដែលអ្នកមានសិទ្ធិលុបចោល លុបចោលសកម្មភាពនោះ[15]។ ប្រសិនបើអ្នកដែលមានសិទ្ធិលុបចោល បានលុបចោលសកម្មភាពដែលអាចលុបចោលបាន សកម្មភាពនោះត្រូវបានចាត់ទុកជាមោឃៈតាំងពីដំបូង ឬនៅក្នុងន័យម្យ៉ាងទៀតសកម្មភាព គឺមានសុពលភាព ទោះបីសកម្មភាពនោះអាចត្រូវបានគេលុបចោលក៏ដោយ ហើយការលុបចោល គឺជាការបង្ហាញឆន្ទៈក្នុងការបដិសេធនូវអានុភាពនោះ។ ឧទាហរណ៍ លោក ស្មៅ បានលក់រថយន្ត និងប្រគល់ទៅឲ្យលោក ទឹកប្រហុក រួចរាល់ហើយ ដោយសារតែលោក ទឹកប្រហុក បានឆបោកទៅលើលោក ស្មៅ។ លោក ទឹកប្រហុក មិនទាន់បានបង់ថ្លៃទិញនៅឡើយទេ ក្រោយពីការលុបចោលកិច្ចសន្យារបស់ លោក ស្មៅ នោះកិច្ចសន្យារវាងលោក ស្មៅ និង លោក ទឹកប្រហុក ត្រូវចាត់ទុកថាមោឃៈតាំងពីដំបូង។ ជាលទ្ធផល លោក ទឹកប្រហុក ត្រូវប្រគល់នូវរថយន្តជាមួយនឹងការប្រាក់ទៅឲ្យលោក ស្មៅ ដោយផ្អែកតាមក្រមរដ្ឋប្បវេណី[16]។

ដូច្នេះជារួមមក គូភាគីនៃកិច្ចសន្យាត្រូវមានការព្រមព្រៀងដោយពិតប្រាកដ និង សេរី ជាក់លាក់ ដើម្បីបង្កើតឲ្យមាននូវសំណើរ និង ស្នីការ មួយដែលជៀសផុតពីបញ្ហានាំឲ្យការបង្កើតកិច្ចសន្យាមានវិការៈនៃការព្រមព្រៀង ក្នុងករណីដែលភាគីម្ខាងមិនមានភាពស្មោះត្រង់ ឬ ឆន្ទៈក្នុងការបង្កើតកិច្ចសន្យា។ ដោយភាគីនោះចង់ប្រើឧបាយកល ដើម្បីជំរុញឲ្យភាគីម្ខាងទៀតចុះកិច្ចសន្យា ក្នុងការទទួលបានប្រយោជន៍ ដែលនាំឲ្យភាគីនៃកិច្ចសន្យាអាចធ្វើការលុបចោល នឹងអាចទាមទារសំណងជម្ងឺចិត្ត ចំពោះការខូចខាតទាំងឡាយ។

---

14 មាត្រា ៣៦០ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

15 មាត្រា ៣៥៨ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

16 មាត្រា ៧៣៧ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

## ឯកសារយោង


១/ ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧។

២/ ក្រឹត្យច្បាប់លេខ ៣៨ ស្តីពីកិច្ចសន្យា និងការទទួលខុសត្រូវក្រៅកិច្ចសន្យា ឆ្នាំ១៩៨៨។